ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
******************

ក្រសួងផែនការ និង ក្រសួងពាណិជ្ជកម្ម
លេខ: ៧៩ ប្រក.ផក.ពណ

ភ្នំពេញ ថ្ងៃទី ០៧ ខែកក្កដា ឆ្នាំ២០០៤

# ប្រកាសរួម
## ស្ដីពី
## វិធានការគ្រប់គ្រងភាពសមស្របតាមបណ្ដា
## លំនាំចំណូតម្ហូបនៃការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ
*******

## រដ្ឋមន្ត្រីក្រសួងផែនការ និងរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយ ប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងផែនការ
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពី ការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/រកម/០៦០០/០០១ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ២០០០ ដែលប្រកាសអោយប្រើច្បាប់ស្ដីពី ការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិតផល ទំនិញ និងសេវា
- បានឃើញ អនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងផែនការ

- បានឃើញ អនុក្រឹត្យលេខ ៥៤អនក្រ.បក ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ០៧ អនក្រ.បក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ស្តីពី ការបង្កើតក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ
- បានឃើញ អនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីអនាម័យនៃម្ហូបអាហារសំរាប់មនុស្ស
- បានឃើញ អនុក្រឹត្យលេខ ៦៩អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ ២០០៣ ស្តីពីការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ
- បានឃើញ ប្រកាសលេខ ៣០ ក.ជ.អ.ជ ចុះថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ២០០៤ ស្តីពីនីតិវិធីគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ
- បានឃើញ ប្រកាសលេខ ០១២ ពណ.បល.ប្រក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ
- ដើម្បីប្រសិទ្ធភាពនៃការត្រួតពិនិត្យល័ក្ខខ័ណ្ឌតម្រូវនៃអំបិលអ៊ីយ៉ូដដែលធ្វើអាជីវកម្ម ។

## សំរេច

**ប្រការ១.**

គ្រប់ប្រភេទអំបិលផលិតក្នុងប្រទេស និងនាំចូលពីបរទេស ចាំបាច់ត្រូវតែបញ្ចូលជាតិអ៊ីយ៉ូដ មុននឹងធ្វើការលក់ចែកចាយដុំនិងរាយនៅតាមទីផ្សារក្នុងព្រះរាជាណាចក្រកម្ពុជា តាមស្តង់ដាកំណត់ ដូចខាងក្រោមនេះ :

- សំណើមក្នុងអំបិលមិនត្រូវលើសពី ៥%
- ត្រូវមានសូដ្យូមក្លរ NaCl យ៉ាងតិច ៩៧% គិតតាមទម្ងន់អំបិលស្ងួត
- មិនត្រូវមានម៉ាញ៉េស្យូមក្លរ $MgCl_2$ លើសពី 0,៥%
- មិនត្រូវមានសារធាតុមិនរលាយក្នុងទឹកលើសពី 0,២%
- មិនត្រូវមានសារធាតុពុលផ្សេងៗលើសពីស្តង់ដារបស់ជាតិឡើយ
- ត្រូវមានសារធាតុអ៊ីយ៉ូដចំនួន :
  - ៥០-៦០ មីលីក្រាម ក្នុង១គីឡូក្រាមអំបិល ពិនិត្យឃើញនៅកន្លែងផលិត
  - ៣០-៦០ មីលីក្រាម ក្នុង១គីឡូក្រាមអំបិល ពិនិត្យឃើញនៅតាមកន្លែងលក់ដុំ និងលក់រាយ ។

**ប្រការ២.**

មុននឹងបញ្ចេញលក់នៅលើទីផ្សារ ផលិតករ អាជីវករទាំងអស់ ត្រូវវេចខ្ចប់អំបិលអ៊ីយ៉ូដ និងផ្សារភ្ជិតយ៉ាងត្រឹមត្រូវក្នុងថង់ផ្លាស្ទិកប៉ូលីអេទីឡែន សំរាប់ប្រភេទទំងន់ ០,៥គក្រ និង ១គក្រ និងបាវផ្លាស្ទិកប៉ូលីប្រូពីឡែន ដែលមាន ស្រទាប់ផ្លាស្ទិកប៉ូលីអេទីឡែននៅខាងក្នុង សំរាប់ប្រភេទទំងន់ ២៥គក្រ និង ៥០គក្រ និងត្រូវប្រតិបត្តិតាមល័ក្ខខ័ណ្ឌកំណត់ ដូចមានចែងក្នុងមាត្រាទី៩ និងទី១០ នៃអនុក្រឹត្យ ៦៩ អនក្រ.បក ចុះថ្ងៃទី២០ ខែតុលា ឆ្នាំ២០០៣ ស្តីពីការគ្រប់គ្រង ការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ ។

**ប្រការ៣.**

ផលិតករអំបិល ត្រូវធានាបង្កើនគុណភាព និងផលិតភាពអំបិល ព្រមទាំងអនុវត្តការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលដើម្បីបំពេញនូវតំរូវការប្រើប្រាស់ទូទាំងប្រទេស ។

**ប្រការ៤.**

អាជីវករអំបិលត្រូវទិញនិងលក់តែអំបិលដែលមានជាតិអ៊ីយ៉ូដ ព្រមទាំងធានានូវគុណភាព និងសុវត្ថិភាព សមស្របតាមស្តង់ដារ និងល័ក្ខខ័ណ្ឌកំណត់ដូចមានចែងក្នុងប្រការ ១ និងប្រការ២ ។

**ប្រការ៥.**

ក្នុងក្របខ័ណ្ឌនៃការទទួលខុសត្រូវរបស់ខ្លួន ផលិតករត្រូវអនុវត្តន៍ឱ្យបានត្រឹមត្រូវនូវបញ្ញត្តិអំពី ស្តង់ដារអំពីលក្ខណៈ និងភាពស្អាតនៃសំបកវេចខ្ចប់ អំពីស្លាកសញ្ញាលើសំបកវេចខ្ចប់ ដែលមានចែងក្នុងប្រការ ១ និងប្រការ២ និងខ្លឹមសារលំអិតមាត្រា ៩ និងមាត្រា ១០ នៃអនុក្រឹត្យលេខ ៦៩ អនក្រ.ប្រក ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០០៣ ស្តីពី ការគ្រប់គ្រងការធ្វើអាជីវកម្មអំបិលអ៊ីយ៉ូដ និងដើម្បីជាមូលដ្ឋានសំរាប់ការត្រួតពិនិត្យដោយមន្ត្រីនាយកដ្ឋានកាំកុងត្រូល សហការជាមួយក្រសួងពាក់ព័ន្ធ ។ ស្របតាមល័ក្ខខ័ណ្ឌកំណត់ដូចខាងលើ សហគ្រាសផលិតទាំងឡាយ ដែលបានទទួលការអនុញ្ញាតផលិតអំបិលអ៊ីយ៉ូដ (IODINE) ត្រូវ :

១-កត់ត្រាក្នុងសៀវភៅបញ្ជីមួយនូវ :

-បរិមាណអំបិលជាវត្ថុធាតុដើមសំរាប់សង្វាក់ផលិតកម្មក្នុងឡូតិនិមួយៗ ។

-បរិមាណសារធាតុសូដ្យូមអ៊ីយ៉ូដួរ ឬប៉ូតាស្យូមអ៊ីយ៉ូដួរ ឬសូដ្យូមអ៊ីយ៉ូដាត ឬប៉ូតាស្យូមអ៊ីយ៉ូដាត ដែលបានទទួលដោយមានរក្សាឯកសារពាក់ព័ន្ធជាមួយ ។

-បរិមាណសារធាតុសូដ្យូមអ៊ីយ៉ូដួរ ឬប៉ូតាស្យូមអ៊ីយ៉ូដួរ ឬសូដ្យូមអ៊ីយ៉ូដាត ឬប៉ូតាស្យូមអ៊ីយ៉ូដាត ប្រើប្រាស់ប្រចាំថ្ងៃ និងតាមឡូតិនិមួយៗ ។

-បរិមាណអំបិលមានបញ្ចូល IODINE ផលិតបានប្រចាំថ្ងៃ និងតាមឡូតិនីមួយៗ ។

២-ធ្វើការត្រួតពិនិត្យភាពត្រឹមត្រូវតាមស្តង់ដារនៃផលិតផលសំរេចជាអាទិ៍ សំណើមនិងកំរិតជាតិអ៊ីយ៉ូដក្នុងអំបិលទម្ងន់ក្នុងបាវតាមចំនួនគំរូតាមសង្វាក់ដែលយល់ថាសមរម្យដោយកត់ត្រានិងរក្សាឯកសារបញ្ជាក់ លទ្ធផលនៃការត្រួតពិនិត្យនិមួយៗនោះ ។

**ប្រការ៦.**

នៅកន្លែងស្តុកទុក នៅកន្លែងលក់ដុំ អាជីវករជាម្ចាស់អំបិលត្រូវមានវិក្កយប័ត្របញ្ជាក់ ប្រភពដើមកន្លែងផលិតអំបិលអ៊ីយ៉ូដ ដែលចេញដោយអាជីវករ រោងចក្រ សហគ្រាស សិប្បកម្ម ដែលបានទទួលការអនុញ្ញាតផលិតអំបិលអ៊ីយ៉ូដ និងលិខិតអះអាង អំពីភាពសមស្របរបស់អំបិល ពីរោងចក្រ សហគ្រាស សិប្បកម្មបញ្ចូលសារធាតុអ៊ីយ៉ូដ ។

**ប្រការ៧.**

ការដឹកជញ្ជូនអំបិលធម្មតាដើម្បីយកមកបញ្ចូលសារធាតុអ៊ីយ៉ូដ នៅរោងចក្រ សហគ្រាស សិប្បកម្មផ្សេងៗ ដែលមានទីតាំងស្ថិតនៅក្នុងទឹដីខេត្តកំពត និងក្រុងកែប ត្រូវមានវិក័យបត្រ័ និងលិខិតដឹកជញ្ជូនត្រឹមត្រូវចេញដោយម្ចាស់សហគ្រាសហើយមានបញ្ជាក់ ជាអាទិ៍នូវទិសដៅដឹកជញ្ជូនគឺ ទីតាំងរបស់រោងចក្រ សហគ្រាស សិប្បកម្ម ដែលទទួលបញ្ចូលសារធាតុអ៊ីយ៉ូដ និងត្រូវសរសេរ ឬ បោះពុម្ពពាក្យថា អំបិលនេះពុំទាន់មានគុណភាពគ្រប់គ្រាន់សំរាប់បរិភោគរបស់មនុស្ស និងសត្វទេ ។

**ប្រការ៨.**

រាល់ការដឹកជញ្ជូនអំបិលធម្មតាយកទៅស្តុកទុក សំរាប់បញ្ចូលសារធាតុអ៊ីយ៉ូដ នៅរោងចក្រ សហគ្រាស សិប្បកម្ម ដែលបានទទួលការអនុញ្ញាត ហើយមានទីតាំងនៅក្នុងទឹដីខេត្តកំពត និងក្រុងកែប ត្រូវមានការអនុញ្ញាតជាមុន ពីនាយកដ្ឋានកាំកុងត្រូល លើមូលដ្ឋាននៃការចុះសិក្សាទិន្នន័យបច្ចេកទេសនិងអាជីវកម្មរបស់សហគ្រាសផលិតនោះ ។

សាខាកាំកុងត្រូលខេត្តកំពត ដែលត្រូវចុះទិដ្ឋាការគ្រប់គ្រងសកម្មភាពដឹកជញ្ជូននេះ ត្រូវកត់ត្រាលើបរិមាណស្តុកឱ្យបានទៀងទាត់តាមបរិមាណដឹកចេញពីចំនួនដែលត្រូវបានអនុញ្ញាតជាគោលការណ៍ ។

**ប្រការ៩.**

រាល់អាជីវកម្មលក់ដុំអំបិលអ៊ីយ៉ូដ ក្រៅពីត្រូវមានការចុះបញ្ជីពាណិជ្ជកម្មតាមបញ្ញត្តិ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និង បញ្ជីពាណិជ្ជកម្មត្រូវមានការប្រកាសសុំធ្វើអាជីវកម្មលក់ដុំអំបិលអ៊ីយ៉ូដនៅសាខាកាំកុងត្រូលនៃកន្លែងធ្វើអាជីវកម្ម ដោយផ្តល់នូវគ្រប់ពត៌មានមានប្រយោជន៍សំរាប់ការត្រួតពិនិត្យជាអាទិ៍ :

- អត្តសញ្ញាណប័ណ្ណ អាស័យដ្ឋានរបស់អាជីវករ
- ទីតាំងសំរាប់អាជីវកម្មលក់ដុំ ឬស្តុកទុក
- ការអះអាងលើរចនាបទរបស់ទីតាំងដែលអាចធានាការទុកដាក់អំបិលអ៊ីយ៉ូដ ក្នុងលក្ខណៈមិនបាត់បង់នូវសារធាតុអ៊ីយ៉ូដពីអំបិល ។

អាជីវករលក់ដុំអំបិលអ៊ីយ៉ូដ ត្រូវរក្សាវិក័យប័ត្របញ្ជាក់ប្រភពរបស់អំបិល ឯកសារដឹកជញ្ជូនប្រគល់-ទទួលអំបិល ឯកសារត្រួតពិនិត្យបញ្ជាក់គុណភាពអំបិលឱ្យបានត្រឹមត្រូវ សំរាប់តំរូវការរបស់មន្ត្រីកាំកុងត្រូលពេលត្រួតពិនិត្យ ។

**ប្រការ១០.**

ការនាំចូលអំបិលធ្វើបានតាមប្រក្រតីតែចំពោះអំបិលមានបញ្ចូលសារធាតុអ៊ីយ៉ូដ (IODINE) ហើយអាជីវករនាំចូលត្រូវធ្វើការប្រកាសបំពេញបែបបទត្រួតពិនិត្យ នៅនាយកដ្ឋានកាំកុងត្រូលពេលទំនិញមកដល់ ។

រាល់ការបញ្ជូនអំបិលតាមមធ្យោបាយនិមួយៗ ត្រូវមានភ្ជាប់បន្ថែមលើឯកសារពាណិជ្ជកម្មពាក់ព័ន្ធនូវវិញ្ញាបនប័ត្របញ្ជាក់ភាពសមស្របតាមស្តង់ដារកំណត់ក្នុងប្រការ១ ។

អត្រាសារធាតុអ៊ីយ៉ូដនៅលើមធ្យោបាយដឹកជញ្ជូន នៅកន្លែងប្រគល់-ទទួល ត្រូវស្មើនឹងកំរិតសារធាតុអ៊ីយ៉ូដ ដែលពិនិត្យឃើញនៅកន្លែងផលិត គឺ៥០-៦០ មីលីក្រាម ក្នុងមួយគីឡូក្រាមអំបិល ។

រាល់ការអនុញ្ញាតឱ្យទទួលចូលឃ្លាំងត្រូវធ្វើក្នុងលក្ខណៈជាប់ល័ក្ខខ័ណ្ឌ នៃការមានភាពសមស្របត្រួតពិនិត្យឃើញបន្ថែមទៀតនៅឃ្លាំងស្តុក ។

**ប្រការ១១.**

ក្រសួងផែនការ ត្រូវសហការជាមួយក្រសួងពត៌មាន ដើម្បីជំរុញផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ អំពីឥទ្ធិពលនៃបញ្ហាកង្វះជាតិអ៊ីយ៉ូដ និងសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ តាមគ្រប់វិទ្យុ ទូរទស្សន៍ ទស្សនាវដ្តី ព្រឹត្តិប័ត្រ សារពត៌មាន និងប្រព័ន្ធពត៌មាននានា ។

មន្ត្រីត្រួតពិនិត្យនៃនាយកដ្ឋានកាំកុងត្រូល ត្រូវកសាងកម្មវិធីត្រួតពិនិត្យជាក់លាក់នៅគ្រប់រោងចក្រ សហគ្រាស សិប្បកម្ម ផលិតអំបិលអ៊ីយ៉ូដ នៅកន្លែងស្តុក កន្លែងលក់ដុំ តាមទីផ្សារ សំដៅធានាអោយការអនុវត្តន៍នូវបទបញ្ញត្តិសំរាប់អាជីវកម្មអំបិលអ៊ីយ៉ូដ បានត្រឹមត្រូវ ។

មន្ត្រីនាយកដ្ឋានកាំកុងត្រូល ត្រូវមានកម្មវិធីធ្វើការផ្សព្វផ្សាយអំពី ឥទ្ធិពលនៃបញ្ហាកង្វះជាតិអ៊ីយ៉ូដ និងសារៈសំខាន់នៃការប្រើប្រាស់អំបិលអ៊ីយ៉ូដ អោយបានសកម្ម ពិសេសសំរាប់ប្រជាពលរដ្ឋនៅជនបទ ។

នាយកដ្ឋានកាំកុងត្រូល ត្រូវខិតខំប្រមូលពត៌មាននានា ធ្វើការវិភាគផ្តល់យោបល់សមហេតុផល មានប្រយោជន៍សំរាប់ពង្រឹងគំរោងអំបិលអ៊ីយ៉ូដជូនក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ និងគណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង ។

**ប្រការ១២.**

ប្រធានគណៈកម្មការបច្ចេកទេសអន្តរក្រសួង គណៈកម្មាធិការសំរបសំរួលការងារអាហារូបត្ថម្ភខេត្ត-ក្រុង អគ្គនាយកបច្ចេកទេសនៃក្រសួងពាណិជ្ជកម្ម ប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៃក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ ប្រធាននាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ-អាហរ័ណ និង បង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ត្រូវអនុវត្តតាមប្រកាសនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រដ្ឋមន្ត្រីក្រសួងផែនការ

ឆាយ ថន

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

លេខ ០៤ [illegible]

ភ្នំពេញ, ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤

វង្ស ចិន្តូតារា

**កន្លែងទទួល:**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាជាតិស្តីពីអាហារូបត្ថម្ភជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- ដូចប្រការ១២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ